មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការធ្វើសេចក្តីសន្និដ្ឋាននៃសក្ខីកម្មរបស់លោក ស៊ីវ ហេងឌ័រ ខណៈពេលដែលនីតិវិធីសួរដេញដោលភស្តុតាងក្នុងសំណុំរឿង០០២វគ្គមួយជិតនឹងបញ្ចប់

*ដោយ សាយមិន ក្រូស័រ*

*ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣*

*ប្រែសម្រួលដោយ គឹមស្រួយ សុខវិសាល*

*នៅព្រឹកនេះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបន្តស្តាប់សក្ខីកម្មចុងក្រោយរបស់សាក្សី ស៊ីវ ហេងឌ័រ ។*

*សាក្សីចាប់ផ្តើមដោយស្នើរសុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យរូបគាត់ ធ្វើការបកស្រាយនូវចំនុចមួយចំនួនទាក់ទងការបកប្រែនិងការប្រើប្រាស់ពាក្យរបស់ខ្មែរក្រហម ។ អង្គជំនុំជម្រះ អនុញ្ញាតនឹងសំណើររបស់សាក្សី ហើយផ្តល់វេទិកាឲ្យសាក្សីធ្វើការបកស្រាយ មុនពេលដែលភាគីនៅក្នុងសំណុំរឿងសួរដេញដោលសាក្សី ។*

*សាក្សីបញ្ជាក់ថាខ្មែរក្រហមមានចេតនាបង្កើតឲ្យមានការប្រើប្រាស់លេខកូដសម្ងាត់ និងអក្សរកាត់ ដើម្បីធ្វើយ៉ាងណាមិនឲ្យអ្នកក្រៅយល់ពីទំនាក់ទំនងរបស់ខ្លួន ។ អ្នកប្រាជ្ញ និងអ្នកស្រាវជ្រាវប្រវត្តសាស្រ្តខ្មែរក្រហមបានយល់ស្របគ្នាលើការបកប្រែភាសារបស់ខ្មែរក្រហម ។ សាក្សីរលើកឡើងថា ពេលដែលគាត់ផ្តល់សក្ខីកម្មកន្លងមក មានបញ្ហាបកប្រែភាសាមួយចំនួនបានកើតឡើង ហើយបញ្ហានេះមិនមែនជាការបកប្រែ ខុសរបស់បុគ្គលិកផ្នែកបកប្រែរបស់តុលាការនោះទេ ។ បញ្ហាបកប្រែនេះកើតឡើងដោយសារបុគ្គលិកផ្នែកបកប្រែរបស់តុលាការមិនបានពិភាក្សា និងយល់ស្របគ្នាក្នុងការប្រើប្រាស់ពាក្យរបស់ខ្មែរក្រហម ។*

## *មេធាវីការពារក្តីខៀវ សំផន សួរដោញដោលសាក្សី*

*មេធាវីការពារក្តី ខៀវ សំផន អង់តា ហ្គីសសេ បន្តសួរដេញដោលសាក្សីពីបញ្ហាបកប្រែជាលាយលក្ខណ៍អក្សរនិងការបកប្រែផ្ទាល់មាត់ ។ មេធាវី ហ្គីសសេ ស្នើរឲ្យសាក្សីនិយាយពាក្យ“គណៈមជ្ឈិម” ជាភាសាខ្មែរ ទាំងពាក្យពេញនិងពាក្យកាត់ ។ សាក្សីលើកឡើងថា នៅពេលដែលយើងនិយាយពាក្យនេះ*

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ក្នុងទម្រង់កាត់ វាធ្វើឲ្យពាក្យនេះមានន័យមិនច្បាស់លាស់ ហើយពាក្យនេះអាចមានអត្ថន័យច្រើន ដូចជា សមាជិករបស់គណៈ ប្រធាន ឬក៏អាចសំដៅទៅលើគណៈទាំងមូលតែម្តង ។

មេធាវី ហ្គីសសេ លើកឡើងថាសហព្រះរាជអាជ្ញាបានដកស្រង់ព័ត៌មាន ចេញពីសៀវភៅរបស់សាក្សី ដែលមានចំណងជើងថា បេក្ខជនប្រាំពីររូបដែលត្រូវនាំមកទោស នៅក្នុងសវនាការថ្ងៃទី១៥ ខែកក្កដា ។ នៅក្នុងអត្ថបទនោះ សាក្សីបានសរសេររៀបរាប់ពីវិធីដែលខ្មែរក្រហមបញ្ជូនរបាយការណ៍ ជូនកាលនិង ជាពិសេសទៅ ប៉ុល ពត ដោយប្រើលេខកូដសម្ងាត់ជូន«០០៩» ឬជូន«បង» ឬក៏ទៅគណៈមជ្ឈិម ដោយប្រើពាក្យថា ជូន«៨៧០» ។ សាក្សីជម្រាបជូនអង្គជំនុំជម្រះថាគាត់អះអាងដូច្នេះ ដោយសារ តែគាត់បានធ្វើការស្រាវជ្រាវលើឯកសារដែលទទួលបានពី ដេវីដ ឆេនដល័រ និងឯកសារដែលមាន នៅមជ្ឈមណ្ឌលឯកសារកម្ពុជារនៅចុងទសវត្សរ៍ឆ្នាំ១៩៩០ ។ សាក្សីបន្ថែមទៀតថា ចាប់ពីពេល សរសេរសៀវភៅនោះមក គាត់បានផ្លាស់ប្តូរការវិភាគរបស់ខ្លួន ដោយមិនគិតរាល់របាយការណ៍ទាំង អស់ត្រូវបញ្ជូនទៅ «៨៧០» ពីព្រោះគាត់ដឹងថាខ្មែរក្រហមបញ្ជូនរបាយការណ៍ទៅកាន់ថ្នាក់ផ្សេងៗ ជា ជាងទៅកាន់ស្ថាប័នជាក់លាក់ណាមួយ ។ សាក្សីប្រៀបធៀប និងចាត់ទុកមន្ទីរ៨៧០ប្រៀបបានទៅនឹង ស្ថាប័នមួយរបស់រដ្ឋការក្រុងវ៉ាស៊ីនតោន ។

សាក្សីបានពិនិត្យមើលបទសម្ភាសន៍រវាង ខៀវ សំផន និង ការិយាល័យចៅក្រមស៊ើបអង្កេតពេល ដែលគាត់ធ្វើការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បទសម្ភាសន៍នោះលើកឡើងថា «មន្ទីរ ៨៧០សំដៅទៅបក្ស ហើយមានន័យថា ប៉ុល ពត។ ប៉ុល ពត ចុះហត្ថលេខាលើឯកសារដែល មានលេខ ៨៧០ ឬ៨៧ ។ ហើយក្រុមការងារ៨៧ ជាផ្នែកមួយនៃមន្ទីរ៨៧០» ។ ប៉ុន្តែ សាក្សី មិនដែលឃើញឯកសារខ្មែរក្រហមណាមួយដែលពន្យល់ពីការប្រើប្រាស់លេខសម្ងាត់នេះទេ ។ សាក្សីនៅ ចាំថា លេខកូដ «៨៧» ត្រូវបានយកមកប្រើប្រាស់ក្រោយខែមករា ឆ្នាំ១៩៧៩ ។ សាក្សីលើកឡើង ថា «ក្រុមការងារ៨៧០» ជាឃ្លាដែលដកស្រង់ពីសក្ខីកម្មរបស់ឌុច ហើយសក្សីមិនដែលឃើញពីមុន មក ទាស់តែសោះ ។ សាក្សីបញ្ជាក់ថាពាក្យនិងលេខសម្ងាត់ទាំងនេះមិនមានន័យច្បាស់លាស់នោះទេ ហើយ មានន័យទៅតាមបរិបទដែលយើងប្រើ ។

មេធាវីការពារក្តី ត្រលប់ទៅពិភាក្សាបទសម្ភាសន៍រវាងសាក្សី និង អៀង សារី ក្នុងឆ្នាំ១៩៩៦ ហើយបានស្នើរឲ្យសាក្សីបញ្ជាក់ពីពាក្យពេជន៍មួយចំនួនដែល អៀង សារី បានប្រើ ។ ពេលនោះ ការ

បកប្រែពីភាសាបារាំងមកភាសាអង់គ្លេសមានបញ្ហានៅព្រឹកនេះ ពីព្រោះមេធាវី ហ្គីសសេ ព្យាយាម យាម និយាយឲ្យលឿន ដើម្បីលើកឡើងចំណុចទាំងអស់របស់ខ្លួន ក្នុងពេលវេលាកំណត់ដែលអង្គជំនុំជម្រះបានប្រគល់ជូន ។ នៅត្រង់ចំនុចបកប្រែដែលដកស្រង់ពីបទសម្ភាសន៍ជាមួយនឹង អៀង សារី មេធាវី ហ្គីស ស្នើរឲ្យសាក្សីពិចារណាការលើកឡើងរបស់ អៀង សារី ដែលថា ខៀវ សំផន និង នួន ជា ទទួល បន្ទុកខាងអប់រំ ហើយ ខៀវ សំផន ជា "ប្រធានមន្ទីរ" ទទួលបន្ទុកខាងខស្សនាហកម្ម ហើយ លឹម ជា "ប្រធានមន្ទីរ"ទទួលបន្ទុកខាងកិច្ចការនយោបាយ ។ ពីដំបូង ប៉ុន ជាអ្នកគ្រប់គ្រងលើមន្ទីរទាំងពីរនេះ ប៉ុន្តែក្រោយពីប៉ុនត្រូវបានសម្លាប់ លឹមបានឡើងកាន់តំណែងនេះ ។

សាក្សីលើកឡើងថា ពាក្យ"មន្ទីរ"នៅក្នុងអត្ថបទនេះសំដៅទៅលើមន្ទីខស្សនាហកម្ម ។ មេធាវី ហ្គីសសេ ចោទសួរសាក្សី ថាតើមន្ទីរមួយណាដែលយើងយកពិភាក្សានេះ ហើយនៅក្នុងសម័យណា ។ សាក្សីបញ្ជាក់ថាពាក្យ"មន្ទីរ" ត្រូវយកមកប្រើនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែមិនមានការបញ្ជាក់ពេលវេលាច្បាស់លាស់នោះទេ ។

សាក្សីបញ្ជាក់ថាមានអ្នកប្រាប់គាត់ថា ប៉ុន ជាប្រធានមន្ទីរ ស-២៧១ ។ មន្ទីរនេះគ្រប់គ្រងមន្ទីរផ្សេងទៀតដែលមានអក្សរកាត់ "ក" ។ សាក្សីបន្ថែមថា លឹម មានឈ្មោះផ្សេងទៀតថា លីន ដែលជាអ្នកទទួលបន្ទុកកិច្ចការរដ្ឋបាលនៃមន្ទីរ៨៧០ ហៅកាត់ ស-៧១ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ។

សាក្សីអះអាងថាពាក្យ "មន្ទីរ"នៅក្នុងបរិបទនេះសំដៅទៅលើមន្ទីរខស្សនាហកម្ម ។ សាក្សីធ្វើការប្រៀបធៀបមន្ទីរ៨៧០ និងមន្ទីរស-៧១ ដោយបញ្ជាក់ថា ៨៧០ សំដៅទៅថ្នាក់លើបក្ស ហើយ ស-៧១ ជាមន្ទីរទទួលបន្ទុកកិច្ចការរដ្ឋបាល ។ សាក្សីពន្យល់ថា ការបែងចែកនេះយកលំនាំរបស់បក្សបក្សកុម្មុយនិសចិន ដែលមានឈ្មោះថា "ការិយាល័យទូទៅរបស់បក្ស" ហើយជាទូទៅ អ្នកដែលផ្តល់បទសម្ភាសន៍មិនដែលបែងចែកពីភាពខុសគ្នារវាងមន្ទីរទាំងពីរ ។

មេធាវីហ្គីសសេ អានបទសម្ភាសន៍របស់ ខៀវ សំផន ជាមួយនឹងការិយាល័យស៊ើបអង្កេត ត្រង់ចំនុចដែលចុងចោទបកស្រាយពីតួនាទីរបស់មន្ទីរ៨៧០ ។ ខៀវ សំផន និយាយថា "ឌឿននិងគាត់ជាអ្នកគ្រប់គ្រងនៅមន្ទីគណៈមជ្ឈិម" ហើយ ឌឿន ទទួលបន្ទុកខាងកិច្ចការនយោបាយ ហើយគាត់ទទួលបន្ទុកខាង "បញ្ជីផលិតផល" របស់ឃុំ ។

សាក្សីដឹងច្បាស់ថា ស-៧១មិនមែនជាមន្ទីនយោបាយរបស់មន្ទីរ៨៧០ នោះទេ។ សាក្សីលើកឡើងថា គាត់មិនដឹងថាកម្មាភិបាលមួយណាដែលគ្រប់គ្រងស-៧១ នោះទេ ដោយសារខ្មែរក្រហមមានចេតនាលាក់បាំងមិនចង់ឲ្យអ្នកក្រៅដឹងពីរឿងសម្ងាត់របស់ខ្លួន។ សាក្សីបន្ថែមថា ខ្មែរក្រហមបង្កើតការលាក់ការណ៍របស់ខ្លួនជាលក្ខណៈប្រពន្ធ័។ តាមរយៈឯកសារដែលសាក្សីបានស្រាវជ្រាវ "ប៉ុនជាអ្នកសម្រេចពីទីតាំងមន្ទីរនេះ នៅថ្ងៃណាក៏ដោយតាមតែចិត្តរបស់គាត់" បើទោះបីជាមន្ទីរនេះមានការិយាល័យចំណុះជាច្រើនក៏ដោយ ឧទាហរណ៍ ក-៧មានទីតាំងនៅមាត់ទន្លេក្នុងក្រុងភ្នំពេញ។

សាក្សីលើកឡើងថា ប៉ុល ពត និង ប៉ុន ស្និទ្ធស្នាលនឹងគ្នាណាស់។ សាក្សីបន្ថែមទៀតថា ហេតុដូច្នេះហើយ វាសឹងតែមិនគួរឲ្យជឿថា ប៉ុន អាចជាជនក្បត់ ហើយមានការភ្ញាក់ផ្អើលក្នុងជួរកម្មាភិបាលខ្មែរក្រហមបានកើតឡើង នៅពេលដែល ប៉ុល ពត បញ្ជាឲ្យសម្លាប់ ប៉ុន។

បន្ទាប់មក មេធាវី ហ្គិសសេ សួរសាក្សីអំពីបទសម្ភាសន៍សាក្សីជាមួយនឹង អៀង សារី ក្នុងឆ្នាំ ១៩៩៦។ សាក្សីលើកឡើងថាពេលនោះ អៀង សារី មានតួនាទីនយោបាយជាប្រធានចលនាសមាគមន៍ជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ ដែលជាស្ថាប័ននយោបាយមួយផ្តាច់ខ្លួនចេញពីជួរខ្មែរក្រហមនៅចុងឆ្នាំ១៩-៩៦។

មេធាវី ហ្គិសសេ បង្ហាញសាក្សីនូវឯកសារដែលមានចំណងជើងថា "ការពិតរបស់របបផ្តាច់ការ ប៉ុល ពត" ហើយសាក្សីបញ្ជាក់ថា គាត់បានអានឯកសារនេះ មុនពេលដែលគាត់ធ្វើបទសម្ភាសន៍ជាមួយ អៀង សារី។ សាក្សីទទួលស្គាល់ថា គាត់បានដឹងពីការផ្តាច់ខ្លួនក្នុងក្នុងជួរខ្មែរក្រហម ពេលដែលគាត់សម្ភាសន៍ អៀង សារី ហើយការផ្តាច់នោះធ្វើឡើងដោយមាន "គម្រោង"។

មេធាវី ហ្គិសសេ លើកយកសក្ខីកម្មរបស់សាក្សីកាលពីថ្ងៃមុន ដែលសាក្សីបានពិភាក្សាពីកំណត់សម្គាល់ជើងទំព័រ៣៦១ នៅក្នុងសៀវភៅ បេក្ខជនទាំងប្រាំពីររូបដែលត្រូវនាំមកទោស។ កំណត់សម្គាល់ជើងទំព័រ៣៦១ ជាអត្ថបទ "របាយការណ៍លម្អិតនៃការស្លាប់"ដោយសរសេរដោយ ណេត ថេយ័រ។ សាក្សីបញ្ជាក់ថា គាត់ពិតជាបានឯកសារយោងនៅក្នុងសៀវភៅរបស់គាត់មែន ហើយ ឯកសារនេះលើកឡើងថា ឌុច បានបញ្ជាក់ថា ខៀវ សំផន បានចូលរួមកិច្ចប្រជុំសម្ងាត់មួយជាមួយនឹង

ប៉ុល ពត ។ សាក្សីមិនបានចាំច្បាស់ថាមានតែឯកសារមួយនេះដែលបង្ហាញពីតួនាទីរបស់ ខៀវ សំផន នោះទេ ។

សាក្សីអះអាងយ៉ាងសង្ខេបថា គាត់បានសម្ភាសន៍ ខៀវ សំផន នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៨០ ជាពេលដែលចុងចោទមានតួនាទីជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

ឯកសារបន្ទាប់ដែលមេធាវីការពារក្ដីលោកមកពិភាក្សាដេញដោល ជាសំបុត្រដែលសាក្សីផ្ញើរទៅកាន់ការិយាល័យស៊ើបអង្កេតកាលពីឆ្នាំ២០០៩ ។ សាក្សីបានសរសេរសំបុត្រហើយភ្ជាប់ជាមួយនឹង សន្និសារព័ត៌មានរបស់ ខៀវ សំផន ។ សាក្សីបានរក្សាទុកឯកសារសន្និសិទ្ធការសែតរបស់ ខៀវ សំផន ពេលដែលគាត់ធ្វើជាអ្នកស្រាវជ្រាវ និងបុគ្គលិកកុងត្រាទទួលបន្ទុកខាងវិភាគ ក្នុងក្រសួងការបរទេសសហរដ្ឋអាមេរិច ។ រដ្ឋភិបាលកម្ពុជាប្រជាធិបតេយ្យបានរៀបចំសន្និសិទ្ធការសែតនេះឡើង នៅក្នុងអំឡុងទស្សនៈកិច្ចមួយ ។ នៅក្នុងដំណើរទស្សនៈកិច្ចនោះ ខៀវ សំផន ជាអ្នកធ្វើសេចក្ដីរាយការណ៍នៅក្នុងសន្និសិទ្ធការសែតនោះ និងបានចំណាយពេលសម្រាប់ធ្វើបទសម្ភាសន៍ជាមួយនឹងអ្នកការសែត ។ សាក្សីបាន ជួប ជនជាប់ចោទនៅពេលស្រស់ស្រូបអាហារ ហើយបានធ្វើបទសម្ភាសន៍ក្រៅផ្លូវការជាមួយនឹង ខៀវ សំផន ។ សាក្សី យល់ស្របជាមួយនឹងមេធាវីការពារក្ដីថា ពេលនោះរដ្ឋាភិបាលកម្ពុជាកម្ពុជាប្រជាធិបតេយ្យ ស្ម័គ្រចិត្តផ្ដល់ព័ត៌មានចេញទៅពិភពខាងក្រៅ ពីព្រោះខ្មែរក្រហមបានអញ្ជើញអ្នកការសែត និងសាក្សីឲ្យចូលរួមក្នុងសន្និសិទ្ធការសែតនោះ ។

ពេលនោះហើយដែលសាក្សីបានជួបនិងសម្ភាសន៍ ខៀវ សំផន ជាលើកទីមួយ ហើយសាក្សីបញ្ជាក់ជូនអង្គជំនុំជម្រះគាត់មិនដែលបានទាក់ទងនឹង ខៀវ សំផន ពីមុនមកឡើយ ។ សាក្សីជម្រាប់ជូនអង្គជំនុំជម្រះថា នៅក្នុងជំនួបនោះ សាក្សីបានណែនាំខ្លួនជាអ្នកស្រាវជ្រាវម្នាក់ ហើយមិនបានប្រាប់ ខៀវ សំផន ថាខ្លួនប្រើប្រាស់ថវិការក្រសួងការបរទេសអាមេរិចសម្រេចការស្រាវជ្រាវនេះទេ ។

បន្ទាប់ពីភាគីនៅក្នុងសំណុំរឿងធ្វើការជំទាស់ និងដោយសារតែពេលដែលត្រូវសួរដេញដោលសាក្សីក៏ជិតអស់ផងនោះ មេធាវី ហ្គីសសេ ដក់ស្រង់សក្ខីកម្មរបស់សាក្សីកាលពីថ្ងៃមុន ដោយផ្ដោតសំខាន់ទៅលើឯកសារដែលបោះពុម្ពផ្សាយនៅឆ្នាំ១៩៨៧ ។ ឯកសារនោះបោះពុម្ពផ្សាយ ក្រោមសម្ភតកិច្ច

ខៀវ សំផន ហើយមានចំណងជើងថា “ការពិតនិងយុត្តិធម៌ទាក់ទងនឹងការសម្លាប់រង្គាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ” ។

មេធាវី ហ្គីសសេ ចោទសួរសាក្សីថា តើការអះអាងថា ខៀវ សំផន ជាអ្នកសរសេរឯកសារនោះ ដោយសារឯកសារនោះមានវិវតែម “អនុប្រធានទទួលបន្ទុកកិច្ចការបរទេស” មែនដែរឬទេ? សាក្សីឆ្លើយតបវិញថា គាត់មិនបានដឹងថាអ្នកណាជាអ្នកសរសេរឯកសារនេះទេ ។

មុនម៉ោងឈប់សម្រាកពេលព្រឹក និងការស្នើរម៉ោងបន្ថែមដើម្បីដេញដោលសួរសាក្សីពីសំណាក់មេធាវី ហ្គីសសេ ចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បញ្ជាក់ថាភាគីគួរតែបញ្ជាក់ប្រាប់អង្គជំនុំជម្រះពីរយៈពេលដែលខ្លួនត្រូវការដើម្បីដោះស្រាយបញ្ហាចាំបាច់មួយចំនួននៅសប្តាហ៍ក្រោយ មុនពេលដែលអង្គជំនុំជម្រះប្រកាស់បិទសវនាការសួរដោញដោលភស្តុតាង ។ ចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ចោទសួរ សហព្រះរាជអជ្ញាពីរយៈពេលដែលសហព្រះរាជអជ្ញាត្រូវការ ដើម្បីលើកឡើងបញ្ហា(ដែលមិនបានកំណត់) ដែលខ្លួនបានលើកឡើងរួចមកហើយនៅក្នុងសារអេឡិចត្រូនិច បន្ទាប់ពីសាក្សីបញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់ ។ សហព្រះរាជអជ្ញា ថារីក អាប់ឌុលហាក់ ឆ្លើយតបថា សហព្រះរាជអជ្ញាត្រូវការពេលតែ១៥ ទៅ២០ នាទីប៉ុណ្ណោះដើម្បីលើកឡើងនូវបញ្ហានេះ ។

លោកប្រធាន និល ណុន យល់ព្រមប្រគល់ពេល១០នាទីទៀតដល់មេធាវី ហ្គីសសេ បន្តសួរដេញដោលសាក្សី និងប្រកាសឲ្យភាគីទាំងអស់សម្រួលឥរិយាបទនៅម៉ោងសម្រាកព្រឹកនេះ ។

បន្ទាប់ពីម៉ោងសម្រាក អង្គជំនុះជម្រះក៏ប្រគល់វេទិការដើម្បីឲ្យមេធាវីការពារសួរដេញដាលសាក្សី ។

មេធាវី ហ្គីសសេ ពិភាក្សាអំពីសន្ទរកថារបស់ ប៉ុល ពត នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ដែលសហព្រះរាជអជ្ញាបានលើកឡើង ។ សន្ទរកថានោះមានចំណងជើងថា “អបអរសាទរខួបកំណើតលើកទី៧០របស់កម្ពុជា” ។ សាក្សីបានសរសេរនៅក្នុងអត្ថបទរបស់ខ្លួនថា ប៉ុល ពត បានលើកឡើងពីគំនិតផ្ទាល់ខ្លួនរបស់គាត់ទាក់ទងនឹងចលនាកុម្មុយនិស្ត ដែលរួមមានទាំងជោគជ័យ និងបរាជ័យ ហើយនឹងគាំទ្រនិងសរសើរ នួន ជា និង ខៀវ សំផន។ បើទោះបីជាមិនបញ្ចេញឈ្មោះ ខៀវ សំផន ក៏ដោយ

ប៉ុល ពត បាននិយាយក្នុងឆ្នាំទសវត្សរ៍ឆ្នាំ១៩៦០ថា “សមមិត្តដែលជាបញ្ញាជនរបស់យើងដូចជា ប្រធានគណៈជាដើម ត្រូវបានចាប់ខ្លួន” ។

នៅក្នុងកថាខណ្ឌនេះ សាក្សីបានសរសេរថា ខៀវ សំផនត្រូវបានចាត់ទុកជាបញ្ញាជនដែលគួរឲ្យគោរពមួយរូប ។ មេធាវី ហ្គីសសេ ចោទសួរសាក្សីថានៅក្នុងបរិបទនៃសុន្ទរកថា ប៉ុល ពត តើ ខៀវ សំផន ជាបញ្ញាជនដែលត្រូវចាប់ខ្លួន ឬជាបញ្ញាជនម្នាក់ដែលទទួលបានការសរសើរហើយត្រូវចាប់ខ្លួន ។ សាក្សីបានជំទាស់ពីរផងនឹងគំនិតផ្ទាល់ខ្លួនរបស់មេធាវី ហ្គីសសេ ។

មុនពេលបញ្ចប់សក្ខីកម្មរបស់ខ្លួន សាក្សីបានជម្រាបអង្គជំនុំជម្រះថា ឈ្មោះបដិវត្តរបស់ ខៀវ សំផន គឺហែម ។

## សហព្រះរាជអជ្ញាឆ្លើយតបនឹងសំបុត្ររបស់មេធាវីការពារក្តី ខៀវ សំផន ទៅកាសែតភ្នំពេញប៉ុស្តិ៍

បន្ទាប់ពីការផ្តល់សក្ខីកម្មរបស់សាក្សីបានបញ្ចប់ សហព្រះរាជអជ្ញា ថារីក អាប់ឌុលហាក់ លើកយកសំបុត្ររបស់មេធាវីការពារក្តី ខៀវ សំផន ដែលផ្ញើរទៅកាន់នាយកការសែតភ្នំពេញប៉ុស្តិ៍ ហើយសំបុត្រត្រូវបានចុះផ្សាយនៅការសែតភ្នំពេញប៉ុស្តិ៍នៅថ្ងៃនោះតែម្តង ។ សំបុត្រនោះមានចំណងជើងថា “ខៀវ សំផន ត្រូវបានបង្ខំឲ្យមិននិយាយស្តី” ហើយមានហត្ថលេខារបស់មេធាវី អង់តា ហ្គីសសេ មេធាវី គង់ សំអុន និងមេធាវី អាកទួរ វ៉ែកកែន ។

សហព្រះរាជអជ្ញា អាប់ឌុលហាក បន្តធ្វើការរិះគន់សំបុត្រនេះ ដោយបកស្រាយការចោទប្រកាន់បែបនេះជារឿង “គួរឲ្យឆ្ងើកឆ្ងល់បំផុត” ហើយបើយោងតាមវិធានផ្ទៃក្នុងទី៣៥ មេធាវីការពារក្តី ខៀវ សំផនសមតែនឹងទទួលបានការប្រមានជាផ្លូវការមួយចំពោះទង្វើបែបនេះ ។ សហព្រះរាជអជ្ញា អាប់ឌុលហាក អះអាងថាទង្វើរបស់មេធាវីការពារក្តី កំពុងតែធ្វើឲ្យរាំងស្ទះកិច្ចដំណើរការស្វែងរកយុត្តិធម៌ និងប្រាស់ចាកឆ្ងាយពីកម្រិតដែលភាគីបានទំពឹងពីមេធាវីទាំងបីរូប ។

បន្ទាប់មក សហព្រះរាជអជ្ញា អាប់ឌុលហាក លើកឡើងនិងឆ្លើយតបនឹងការចោទប្រកាន់ប្រាំចំណុច ដែលបានសរសេរឡើងនៅក្នុងសំបុត្រនោះ ។

១. មានការលើកឡើងថា ចៅក្រមបានស្តាប់ការផ្តល់សក្ខីកម្មរបស់សាក្សីជាច្រើន និងដាក់បញ្ចូលឯកសាររាប់ពាន់ចូលទៅក្នុងសំណុំរឿង ប៉ុន្តែមិនបានយកចិត្តទុកដាក់នឹងសំណើសុំរបស់មេធាវីការពារក្តីឡើយ ។ សហព្រះរាជអជ្ញា អាប់ឌុលហាក លើកឡើងថាកាចោទប្រកាន់គឺខុសទាំងស្រុង ។ សហព្រះរាជអជ្ញាបន្ថែមថា នៅកាលៈទេសៈណាក៏ដោយ អង្គជំនុំជម្រះតែងតែផ្តល់ឱកាសឲ្យមេធាវីការពារក្តីជំទាស់និងដេញដោលលើភស្តុតាង និងដាក់ឯកសាររបស់ខ្លួន ហើយការដែលមេធាវីការពារក្តីលើកឡើងថាសំណើសុំរបស់ក្រុមខ្លួនមិនត្រូវបានអង្គជំនុំជម្រះយកទៅពិចារណានោះគឺ «ពិតជាខុសទាំងស្រុង» ។ ការចោទប្រកាន់របស់មេធាវីការពារក្តី «គ្មានហេតុផល គ្មានក្រមសីលធម៌ និងគ្មានវិជ្ជាជីវៈ» ទាល់តែសោះ ។

២. មានការលើកឡើងថា «ការពិភាក្សាដេញដោលដាក់លាក់» ពីការឯកសារជាច្រើនដែលបានដាក់បញ្ចូលក្នុងសំណុំរឿងត្រូវបានច្រានចោល ។ ឆ្លើយតបនឹងការចោទប្រកាន់នេះ សហព្រះរាជអជ្ញា អាប់ឌុលហាក លើកឡើងថាព្រះរាជអជ្ញាមានចង្កល់ថាតើ ក្រុមមេធាវីការពារក្តីកំពុងតែដើរលើផ្លូវស្របគ្នាជាមួយនឹងភាគីដ៏ទៃដែរឬអត់ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានបដិសេធមិនបង្ហាញឯកសារបើទោះបីជាសហព្រះរាជអជ្ញាបានស្នើរថា មេធាវីការពារនៅមានពេលវេលាបន្ថែមដើម្បីធ្វើបទបង្ហាញរបស់ខ្លួន ។ សហព្រះរាជអជ្ញប្រកាសថា «ការចោទប្រកាន់បែបនេះគឺជារឿងអាម៉ាសមួយ» ។

៣. មានការលើកឡើងថា ដីការបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះមិនមានយុត្តិធម៌ ។ សហព្រះរាជអជ្ញាអាប់ឌុលហាក បកស្រាយថាការលើកឡើងពីបញ្ហាបំបែកសំណុំរឿងនេះ «គួរឲ្យអស់សំណើច» ពីព្រោះមេធាវីការពារក្តីបានគាំទ្រដីការបំបែកសំណុំរឿងនេះតាំងសវនាការដំបូងមកម្ល៉េះ ។ សហព្រះរាជអជ្ញាបន្ថែមថា «អង្គជំនុំជម្រះបានប្រកាសថានឹងសម្រេចជាផ្លូវការលើគោលការណ៍ព្រហ្មទណ្ឌ» ហើយមេធាវីការពារក្តីមាន «ការភ្ញាក់ផ្អើល» ចំពោះការសម្រេចនេះ ។ សហព្រះរាជអជ្ញា លើកឡើងថា មេធាវីការពារក្តីមិនបានធ្វើការចោទសួរលើដីការបំបែកសំណុំរឿង ឬក៏ស្នើរសុំឲ្យមានការពិចារណាឡើងវិញទាក់ទងនឹងដីការបំបែកសំណុំរឿងនេះ ហើយថែមទាំងមិនបានជំទាស់នឹងការស្នើរសុំរបស់ព្រះ

រាជអាជ្ញាពីការចុះពិនិត្យទីតាំងស្ថិតក្រោមការស៊ើបអង្កេតរបស់តុលាការម្តងទៀត ។ សហព្រះរាជអាជ្ញា ចាត់ទុកការចោទប្រកាន់ទីបីនេះជា «សកម្មភាពមិនស្មោះត្រង់និងមិនអាចទុកចិត្តបាន» ។

៤. មានការលើកឡើងថា មេធាវីការពារក្តី «នឹងគ្មានឱកាសឈ្លោះក្តីនេះទេ» ដោយសារតែអង្គជំនុំជម្រះមិនដែលយកការលើកឡើងរបស់មេការពារក្តីមកធ្វើការពិចារណានោះទេ : សហព្រះរាជអាជ្ញា អាប់ឌុលហាក ចាត់ទុកការចោទប្រកាន់នេះជារឿង «គួរឲ្យអស់សំណើចនិងមិនពិត» ។ សហព្រះរាជអះអាងថា មេធាវីការពារមានពេលវេលាស្មើរគ្នានឹងភាគីដ៏ទៃទៀតដែរក្នុងការសួរដេញដោលសាក្សីបាន កោះហៅសក្ខីរបស់ខ្លួនមកធ្វើសក្ខីកម្ម មានឱកាសលើកយកសំណើរសុំរបស់ខ្លួនមកដេញដោលនៅក្នុងសវនាការ ហើយមេធាវីការពារក្តីខ្លួនឯងផ្ទាល់មិនដែលជំទាស់នឹងចំនុចទាំងអស់នេះទេ ។ សហព្រះរាជអាជ្ញាបន្ថែមថានៅថ្ងៃទី ២៧ ខែសភាថ្មីៗនេះ ខៀវ សំផន បាននិយាយថាគាត់នឹងឡើងមកបកស្រាយដោយមិនជំទាស់នោះទេ ។

៥. មានការលើកឡើងថា ខៀវ សំផន មិនព្រមផ្តល់សក្ខីកម្មដោយសារតែអង្គជំនុំជម្រះបានបដិសេធនឹងសំណើរទាំងអស់របស់ចុងចោទរូបនេះ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះបានទទួលយកសំណើរមួយចំនួនរបស់ចុងចោទ និងបដិសេធនឹងសំណើរផ្សេងទៀតរបស់ចុងចោទផងដែរ ហើយការសេចក្តីសម្រេចបែបនេះ វាដូចគ្នានឹងសម្រេចនៅតុលាការអន្តរជាតិដ៏ទៃទៀតដែរ ។ សហព្រះរាជអាជ្ញា អាប់ឌុលហាក បានលើកឡើងថាសហព្រះរាជអាជ្ញាស្នើរសុំសិទ្ធិបន្ថែមទៀត ។ សហព្រះរាជអាជ្ញា អាប់ឌុលហាក បន្ថែមថាព័ត៌មានទាំងនេះមិនមាននៅក្នុងសំបុត្រដែលមេធាវីការពារក្តីផ្ញើរទៅការសែតភ្នំពេញប៉ុស្តិ៍ ។

ដើម្បីដោះស្រាយការចោទប្រកាន់មិនពិតទាំងអស់នេះ សហព្រះរាជអាជ្ញា អាប់ឌុលហាក លើកឡើងពីពីការគម្រោងដែលបានបង្កើតដើម្បីដោះស្រាយនឹងការចោទប្រកាន់មិនពិតបែបនេះ ។

បន្ទាប់ សាក្សីអះអាងថា ទង្វើរបស់មេធាវីការពារក្តីជាការរំលោភបំពានទៅលើ សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិពីគោលការណ៍ទូទៅនៃតួនាទីរបស់មេធាវី ។សហព្រះរាជអាជ្ញាបន្ថែមថា «អ្នកមានវិជ្ជាជីវៈជាមេធាវីគួរតែបានអានឯកសារនេះ» ហើយអានមាត្រាមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ :

> មាត្រា១៧៖ ក្នុងនាមជាភ្នាក់ងារដ៏សំខាន់ម្នាក់នៅក្នុងប្រព័ន្ធយុត្តិធម៌ មេធាវីត្រូវតែបំពេញវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយកិត្តិយសនិងសេចក្តីថ្លៃថ្នូរគ្រប់ពេល ។
>
> មាត្រា១៨៖ដើម្បីការពារសិទ្ធិរបស់កូនក្តីខ្លួន និងលើកកម្ពស់ប្រព័ន្ធយុត្តិធម៌ មេធាវីត្រូវតែការពារសិទ្ធិមនុស្សនិងសិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋដែលទទួលស្គាល់ដោយច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិ ហើយមេធាវីត្រូវបំពេញកិច្ចការរបស់ខ្លួនដោយសេរីនិងយកចិត្តទុកដាក់ដោយយោង តាមច្បាប់និងក្រមសីលធម៌វិជ្ជាជីវរបស់មេធាវី ។

មុននឹងបញ្ចប់ សហព្រះរាជអជ្ញា អាប់ឌុលហាក ចាត់ទុកសំបុត្ររបស់មេធាវីការពារក្តីថាធ្វើឡើងដោយមិនមានការពិចារណាឲ្យបានដិតដល់ និងមានចេតនាធ្វើឲ្យសាធារណជនយល់ច្រឡំ ។ សហព្រះរាជអជ្ញាបន្តថា មេធាវីការពារក្តីសរសេរសំបុត្រនេះឡើង ដោយមិនបានគិតពីក្រមសីលធម៌វិជ្ជាជីវរបស់ខ្លួនជាមេធាវីហើយស្នើរឲ្យអង្គជំនុំជម្រះប្រើវិធានផ្ទៃក្នុង៣៥ ជាការប្រមាន និងបញ្ជូនបញ្ហានេះទៅឲ្យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីដោះស្រាយ ។

សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ុណូហ្វត គាំទ្រសំណើរសហព្រះរាជអជ្ញាដោយចោទក្រុមមេធាវីការពារក្តី ខៀវ សំផន ថាបានសរសេរសំបុត្រ «មិនពិតនិងមិនស្មោះត្រង់» ។ មេធាវី ស៊ីម៉ុណូហ្វត លើកឡើងថា ដោយសារមេធាវីការពារក្តីមិនសូវបញ្ចេញមតិនៅក្នុងសវនាការក្រុមរបស់គេអាចនិយាយយ៉ាងស្រួលថា តុលាការហាមឃាត់ក្រុមរបស់គេមិនឲ្យបញ្ចេញមតិ ។ ការសែតមិនមែនជាវេទិការសម្រាប់ឲ្យភាគីពិភាក្សាតតាំងគ្នានោះទេ ។ មេធាវី ស៊ីម៉ុណូហ្វត បន្ថែមថា គាត់«សោកស្តាយ» ចំពោះសំបុត្ររបស់មេធាវីការពារដែលបានចេញផ្សាយជាសាធារណៈ ។

សហការណីរបស់ មេធាវី ស៊ីម៉ុណូហ្វត គឺលោកមេធាវី ពេជ អង់ លើកឡើងពីសិទ្ធិនៅស្ងៀមមិនបញ្ចេញមតិ ហើយស្នើរសុំឲ្យអង្គជំនុំជម្រះជម្រុញឲ្យចុងចោទធ្វើសក្ខីកម្ម ។

លោកប្រធាន និល ណុន សង្ខេបនីតិវិធីដែលបានលើកយកពិភាក្សានិងដេញដោលនៅថ្ងៃនេះ ដោយមិនបានចាប់អារម្មណ៍ថាមេធាវីការពារក្តី ខៀវ សំផន មានឱកាសធ្វើការឆ្លើយតបនឹងការចោទប្រកាន់របស់ភាគីមកលើក្រុមរបស់ខ្លួន ។

មេធាវីការពារ ហ្គីសសេ ផ្ដើការបកស្រាយនឹងការចោទប្រកាន់របស់ភាគីដ៏ទៃទៀត មកលើក្រុមរបស់ខ្លួនយ៉ាងលឿន ហើយមិនបានគិតថា គាត់ត្រូវនិយាយមួយៗ ដើម្បីឲ្យអ្នកបកប្រែអាចបកប្រែពាក្យពេជន៍ដែលគាត់និយាយទាន់ៗ ទី១ មេធាវី ហ្គីសសេ អះអាងថាក្រុមមេធាវីការពារក្ដីរបស់ខ្លួនមិនដែលមានចេតនាប្រមាថអង្គជំនុំជម្រះ និងប្រជាជនកម្ពុជានោះទេ ។ ទីពីរ មេធាវីការពារក្ដីមានការតព្វកិច្ចការពារកូនក្ដីរបស់ខ្លួន ។ មេធាវី ហ្គីសសេ បន្ថែមថារាល់ព័ត៌មានទាំងអស់នៅក្នុងសំបុត្រនោះសុទ្ធតែបានលើកឡើងមកដេញដោលនៅចំពោះមុខអង្គជំនុជម្រះ ។

មេធាវី ហ្គីសសេ បកស្រាយពីការរិះគន់ថាវាជារឿង«គួរឲ្យឆ្ងើកឆ្ងើលបំផុត» ដែលក្រុមមេធាវីការពារមិនបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបំបែកសំណុំរឿង ដោយលើកហេតុផលថា មេធាវីការពារក្ដី ខៀវ សំផន បានសរសេរនិងបង្ហាញថាដីការនេះក្នុងទម្រង់ជាការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ។

បន្ទាប់មកទៀត មេធាវី ហ្គីសសេ បញ្ជាក់ព័ត៌មានដែលលើកឡើងនៅក្នុងសំបុត្រសុទ្ធតែជាអ្វីដែលភាគីបានពិភាក្សារួចមកហើយ ។

មេធាវីការពារក្ដី ហ្គីសសេ អានកំណត់ត្រារបស់ខ្លួន ហើយបញ្ចប់សេចក្ដីថ្លែងការណ៍ ដោយលើកឡើងថាសហព្រះរាជអជ្ញាបានកំណត់ចំនួនទំព័រសម្រាប់សារណាបញ្ចប់ ក្រោយពេលការស្លាប់របស់ អៀង សារី និងមិនមានកំណត់ចំនួនទំព័រសម្រាប់សារណារបស់ភាគី ពេលបែកសវនាការដំបូង ។

មេធាវី គង់ សំអុន លើកឡើងថាព្រះរាជអជ្ញាមិនបានពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយពីអត្ថន័យរបស់សំបុត្រមេធាវីការពារក្ដី ។ មេធាវី គង់ សំអុន បញ្ជាក់ថា "ការចោទប្រកាន់ថាមេធាវីការពារក្ដីរបស់ខ្លួនបានលុកដៃនៅក្នុងកិច្ចការអង្គជំនុំជម្រះ គឺជាការយល់ខុស ហើយការយល់ខុសបែបនេះ កើតឡើងដោយសារតែភាគីមិនបានដឹងពីគោលជំហររបស់មេធាវីការពារក្ដី" ។ ចុងក្រោយ មេធាវី គង់ សំអុន លើកឡើងថា សិទ្ធិនៅស្ងៀមមិនបញ្ចេញមតិគឺសិទ្ធិមូលដ្ឋានរបស់ចុងចោទ ហើយ ខៀវ សំផន ជាអ្នកសម្រេចថាគាត់អាចទុកចិត្តអង្គជំនុំជម្រះឬអត់ ។ មេធាវី គង់ សំអុន លើកឡើងទៀតថា នេះគឺជាតុលាការ មិនមែនជាថ្នាក់រៀននោះទេ ។

លោកប្រធានសាលាដំបូងប្រកាសបិទសវនាការ ហើយអង្គជំនុំជម្រះនឹងបន្តស្តាប់ការស្នើសុំផ្សេងៗរបស់ភាគី និងប្រកាសពីការបរិឆ្ឆេតពេលវេលាសម្រាប់នីតិវិធីសំណុំរឿង០០២វគ្គមួយ នៅសវនាការថ្ងៃអង្គារ៍ ទី២៣ ខែកក្កដា ឆ្នាំ២០១៣ ។

**-ចប់-**